00282970

D55/I/12

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

សំណុំរឿងលេខ:០០២/១៩-០៩-២០០៧-អ.វ.ត.ក/ស.ច.ស(អ.ប.ជ ០៦)

| | |
|---|---|
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន: | ១៩ ខែកុម្ភៈ ឆ្នាំ ២០០៩ |
| ភាគីបញ្ជូន: | សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី |
| ភាសាដើម: | ខ្មែរ និងអង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 02 / 2009
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

---

**លិខិតរំលឹករបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំអោយឆ្លើយតបទៅនឹងសំណើរឲ្យពិចារណាឡើងវិញចំពោះការវាយតម្លៃទៅលើឋានានុក្រមគតិយុត្តិរបស់វិធានផ្ទៃក្នុងនៅក្នុងសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ជំទាស់នឹងដីកាបដិសេធសុំអោយនាព**

---

បញ្ជូនដោយ ៖

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

លោក ហុង គឹមសួន

លោក យុង ផានិត

លោក គង់ ពិសី

លោក ឡោ ជុនធី

លោក នី ចាន់ឌី

កញ្ញា Silke STUDZINSKY

លោក គឹម ម៉េងឃី

លោកស្រី Martine JACQUIN

លោក Philippe CANONNE

គោរពជូន ៖

អង្គបុរេជំនុំជម្រះ

លោក ប្រាក់ គឹមសាន

លោក Rowan DOWNING

លោក ន័យ ថុល

លោកស្រី Katinka LAHUIS

លោក ហ៊ួត វុទ្ធី

<u>ចម្លងជូន៖</u>

ការិយាល័យ សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Robert PETIT

សហមេធាវីការពារ ជនត្រូវចោទ នួន ជា

លោក សុន អារុណ

លោក Nichel Pestman

លោក Victor Koppe

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 19 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fay

១- កាលពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានចេញសេចក្តីសម្រេចទៅលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាបដិសេធសំណើសុំមោឃភាព។ នៅក្នុងសេចក្តីសម្រេចនោះ អ.ប.ជ បានលើកឡើងអំពីទំនាក់ទំនងរវាងក្រមនីតិវិធីព្រហ្មទណ្ឌ និងវិធានផ្ទៃក្នុង ដែលថាវិធានចុងក្រោយនេះបង្កើតនូវប្រព័ន្ធច្បាប់នីតិវិធីដោយខ្លួនផ្ទាល់ ហើយដែលមិនផ្ទុយគ្នាជាមួយក្រមនីតិវិធីព្រហ្មនោះទេ។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតុបករណ៍ចំបង ដែលយើងគួរយកមកពិនិត្យមើលក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រមនីតិវិធីព្រហ្មទណ្ឌគួរអនុវត្តតែក្នុងករណីដែលវិធានផ្ទៃក្នុងមិនបានចែង ឬចែងមិនច្បាស់លាស់តែប៉ុណ្ណោះ[1] ។

២- សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់សំណើរួមមួយកាលពីថៃទី១៣ ខែតុលា ឆ្នាំ២០០៨ ទៅអង្គបុរេជំនុំជម្រះ ដើម្បីឲ្យពិចារណាឡើងវិញ(**សំណើរសុំពិចារណាឡើងវិញ**)[2] ទៅលើការវាយតម្លៃចំពោះឋានានុក្រមរបស់វិធានផ្ទៃក្នុងនៅក្នុងសេចក្តីសំរេចខាងលើ។

៣- នៅក្នុងសំណើសុំឲពិចារណាឡើងវិញនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូននូវហេតុផលជាច្រើនដែលគាំទ្រដល់សំណើនេះ ។ ទី១ គឺថាវិធានផ្ទៃក្នុងត្រូវបានអនុម័តដោយកិច្ចប្រជុំពេញអង្គរបស់ក្រុមចៅក្រមនៃអ.វ.ត.ក ដែលជាធម្មតាស្ថាប័ននេះមិនមានអំណាចអនុម័តប្រព័ន្ធច្បាប់នីតិវិធីដោយខ្លួនផ្ទាល់នោះទេ ។ មានតែសភាប៉ុណ្ណោះដែលមានអំណាចនីតិបញ្ញត្តិ ទាំងកិច្ចព្រមព្រៀងស្តីពីការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងទាំងច្បាប់ស្តីពីអង្គជំនុំជម្រះវិសាមញ្ញមិនបានធ្វើប្រតិភូកម្មអំណាចធ្វើច្បាប់នេះទៅអោយកិច្ចប្រជុំពេញអង្គរបស់ក្រុមចៅក្រមនោះទេ ។ ពួកគេមិនត្រូវបានផ្តល់ឲ្យនូវអំណាចធ្វើច្បាប់ ហើយក៏មិនអាចដណ្តើមយកអំណាចនេះដោយគ្រាន់តែលើកឡើងត្រឹមតែជាទស្សនៈនោះទេ ។ ទី២ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាវិធានផ្ទៃក្នុង បើទោះបីជាវាមានសុពលភាពក្តី ប៉ុន្តែឋានានុក្រមរបស់វាទាបជាងក្រមនីតិវិធីព្រហ្មទណ្ឌបើផ្អែកទៅលើគោលការណ៍ច្បាប់ដែលមានឋានានុក្រមទាបគោរពច្បាប់ដែលមានឋានានុក្រមខ្ពស់ ហើយសេចក្តីសំរេចរបស់អង្គបុរេជំនុំជម្រះគឺមានការភាន់ច្រលំទៅលើបញ្ហាច្បាប់ និងបង្កើត/

[1] សំណុំរឿងនួន ជា ០០២/១៩-៩-២០០៧-អវតក/កសចស(អបជ០៦) សេចក្តីសំរេចទៅនឹងបណ្តឹងឧទ្ធរហ៍របស់ នួន ជា ប្រឆាំងនឹងដីកាបដិសេធសំណើសុំមោឃភាព ចុះថ្ងៃទី២៦-សីហា-២០០៨ លិខិតលេខ៥៥/I/៧៨កឋាខណ្ឌទី ១៤-១៥

[2] សំណុំរឿងនួន ជា ០០២/១៩-៩-២០០៧-អវតក/កសចស(អបជ០៦) សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យពិចារណាឡើងវិញចំពោះការសំរេចទៅលើសំណើសុំមោឃភាពរបស់ នួន ជា លិខិតលេខ៥៥/I/៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៨

នូវភាពអយុត្តិធម៌ដល់ដើមបណ្តឹងរដ្ឋប្បវេណី ។

៤- សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ស្នើជូនទៅ អ.ប.ជ (១) ពិចារណាឡើងវិញចំពោះការសំរេចរបស់ខ្លួនដែលទាក់ទងទៅនឹងទំនាក់ទំនងរវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌ និង (២) ក្នុងករណីដែលវិធានផ្ទៃក្នុងមានសុពលភាព ដោយផ្អែកច្បាប់ដែលពាក់ព័ន្ធ ស្នើសុំឲ អ.ប.ជ សំរេចថា ក្រមនីតិវិធីព្រហ្មមានអនុភាពអនុវត្តខ្ពស់ជាង ក្នុងករណីបើវិធាននីតិវិធីទាំងពីរនេះមានចំនុចមិនត្រូវគ្នា។

៥- សំណើសុំពិចារណាឡើងវិញនេះ ត្រូវបានដាក់ជូនទៅ អ.ប.ជ អស់រយៈពេលជាងបួន(៤)ខែមកហើយ ប៉ុន្តែរហូតដល់ពេលនេះ អ.ប.ជ មិនទាន់បានឆ្លើយតបនៅឡើយទេ ។ ការខកខានក្នុងការឆ្លើយតបរបស់ អ.ប.ជ នេះ បានបណ្តាលឲប៉ះពាល់ដល់សវនាការដែលនឹងត្រូវធ្វើឡើងជាបន្តបន្ទាប់ខាងមុខទៀត តួយ៉ាងសវនាការថ្ងៃទី ២៤ ខែគុម្ភះ ឆ្នាំ២០០៩ និងថ្ងៃទី២៧ ខែគុម្ភះ ឆ្នាំ២០០៩ ជាដើម ។

៦- នៅក្នុងសវនាការរបស់ អ.ប.ជ លើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែសំណុំរឿងរបស់លោក ខៀវ សំផន ដោយសហចៅក្រមស៊ើបអង្កេត សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការថ្លែងដោយផ្ទាល់មាត់ក្នុងសវនាការដែលត្រូវបានអនុញ្ញាតឲ្យដោយក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បើទោះបីជាខ្លួនមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរជាមុនយ៉ាងណាក្តី ប៉ុន្តែនៅក្នុងពេលនោះ អ.ប.ជ បានចេញសេចក្តីសម្រេចដោយបដិសេធសិទ្ធិក្នុងការថ្លែងដោយផ្ទាល់មាត់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរង្វង់សវនាការ[3]។ សំអាងហេតុនៅក្នុងសេចក្តីសម្រេចចុងក្រោយនេះ អ.ប.ជ យោងតែទៅលើសេចក្តីសម្រេចចុះថ្ងៃទី២៦ ខែសីហាឆ្នាំ២០០៨ លើបណ្តឹងរបស់ នួន ជានិងសេចក្តីសម្រេច ទាក់ទងទៅនឹងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៨ នួន ជា ប៉ុណ្ណោះ តែមិនបានឆ្លើយតបទៅនឹងសំណើសុំពិចារណាឡើងវិញនោះឡើយ ។

---

[3] សំណុំរឿង ខៀវ សំផន ០០២/១៩-៩-២០០៧-អវតក/កសចស(អបជ០១១) សេចក្តីសំរេចលាយលក្ខទៅលើសំណើផ្ទាល់មាត់របស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងការថ្លែងដោយផ្ទាល់មាត់ លិខិតលេខ A ១៩០/I/៦ ចុះថ្ងៃទី៤-១២-២០០៨

៧- សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទន្ទឹងរង់ចាំដោយសេចក្តីគោរពនូវការសំរេចមួយដែលសមហេតុផលឆ្លើយតបទៅនឹងសំណើដែលបានដាក់ជូន មុនពេលការបើកសវនាការបណ្តឹងឧទ្ធរណ៍ទាំងឡាយដែលនឹងធ្វើឡើងជាបន្តបន្ទាប់នៅចុងខែនេះ ។

**ហេតុដូច្នេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមស្នើសុំទៅអង្គបុរេ ៖**

ធ្វើការឆ្លើយតបចំពោះសំណើសុំឱ្យពិចារណាឡើងវិញរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៨ ឱ្យបានកាន់តែឆាប់តាមដែលអាចធ្វើទៅបាន ។

**សូមអង្គបុរេទទួលនូវការគោរពអំពី ៖**

មេធាវី ឡោ ជុនធី
មេធាវីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

មេធាវី ហុង គីមសួន
មេធាវីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

មេធាវី នី ចាន់ឌី
មេធាវីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា

មេធាវី គង់ ពិសី
មេធាវីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

មេធាវី យ៉ុង ផានិត
មេធាវីក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា

កញ្ញាមេធាវី Silke Studzinsky
សហមេធាវីអន្តរជាតិ

លោកមេធាវី គីម ម៉េងឃី
មេធាវីអង្គការមេធាវីគ្មានព្រំដែន

មេធាវី Martine Jacquin
មេធាវីអង្គការមេធាវីគ្មានព្រំដែន

មេធាវី Philippe Canonne

មេធាវីអង្គការមេធាវីគ្មានព្រំដែន

ធ្វើនៅភ្នំពេញ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៩